ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ
សាលាខេត្តព្រៃវែង
លេខ ០១៣/សជណ /១១

# សេចក្តីជូនដំណឹង
## ស្តីពីពន្ធសត្តឃាត

- បានឃើញអនុក្រឹត្យលេខ ០៧ អនក្រ ចុះថ្ងៃទី ២០ ខែឧសភា ឆ្នាំ១៩៩១ ស្តីពីការប្រមូលពន្ធសត្តឃាត
- បានឃើញប្រកាសលេខ ០៣៦ កហវ.ពដ ចុះថ្ងៃទី ៣០ ខែកញ្ញា ឆ្នាំ១៩៩១ របស់ក្រសួងហិរញ្ញវត្ថុ ស្តីពីការណែនាំអនុវត្តអនុក្រឹត្យស្តីពីពន្ធសត្តឃាត។

អភិបាលនៃគណៈអភិបាលខេត្តសូមធ្វើការណែនាំ និងជូនដំណឹងដូចតទៅះ

១- ពន្ធសត្តឃាតត្រូវប្រមូលលើគ្រប់សមាសភាពសេដ្ឋកិច្ច ដែលសម្លាប់សត្វគោ ក្របី ជ្រូក យកសាច់។

២- ពន្ធសត្តឃាតត្រូវប្រមូលតាមតារាងខាងក្រោមះ

| ល.រ | ប្រភេទសត្វ | ថ្លៃគិតពន្ធក្នុង១ក្បាល | អត្រាពន្ធ | ប្រាក់ពន្ធសត្តឃាត |
|---|---|---|---|---|
| ១ | ជ្រូក | ៥០.០០០៛ | ៣% | ១.៥០០៛ |
| ២ | គោ | ១០០.០០០៛ | ៣% | ៣.០០០៛ |
| ៣ | ក្របី | ១០០.០០០៛ | ៣% | ៣.០០០៛ |

៣- ពន្ធសត្តឃាតត្រូវប្រមូលនៅកន្លែងពិឃាតសត្វ ឬ នៅសត្តឃាតដ្ឋាន។

៤- ម្ចាស់សត្តឃាតដ្ឋាន ឬ ម្ចាស់កន្លែងពិឃាតសត្វត្រូវកាន់បញ្ជីគណនេយ្យ។

៥- ប្រចាំខែនៅរៀងរាល់ថ្ងៃទី ២៥ ម្ចាស់សត្តឃាតដ្ឋាន ឬ កន្លែងពិឃាតសត្វ ត្រូវផ្អែកលើបញ្ជីគណនេយ្យដើម្បីធ្វើលិខិតឆ្លើយប្រកាសអំពីប្រភេទសត្វ ចំនួនសត្វដែលបានសម្លាប់ឲ្យបានទៀងត្រង់ ពិតប្រាកដ ជូនអង្គភាពពន្ធដារដែលបានគ្រប់គ្រង។

៦- អ្នកជាប់ពន្ធសត្តឃាត ត្រូវបង់ពន្ធសត្តឃាតយ៉ាងយឺតបំផុតនៅថ្ងៃទី ១០ នៃខែបន្ទាប់។

៧- ករណីមានការតវ៉ា អំពីប្រាក់ពន្ធសត្តឃាត ឬ ប្រាក់ពិន័យ អ្នកជាប់ពន្ធត្រូវតែបង់ពន្ធសត្តឃាត ឬ ប្រាក់ពិន័យឲ្យបានគ្រប់ចំនួនជាមុនសិន រង់ចាំការដោះស្រាយបណ្តឹងតវ៉ាជាក្រោយ។

៨- ករណីអ្នកជាប់ពន្ធពុំព្រមបង់ពន្ធសត្តឃាតតាមរយៈពេលកំណត់ ត្រូវទទួលរងការអនុវត្តន៍វិធានការតឹងទារបំណុលពន្ធ។

ទទួលបាននូវសេចក្តីជូនដំណឹងនេះ អភិបាលនៃគណៈអភិបាលខេត្តមានជំនឿថា គ្រប់អ្នកជាប់ពន្ធសត្តឃាតទាំងអស់នឹងយកចិត្តទុកដាក់បំពេញកាតព្វកិច្ចបង់ពន្ធ បានទាន់ពេលវេលាកំណត់ជាមិនខានឡើយ។

ព្រៃវែង,ថ្ងៃទី ០១ ខែធ្នូ ឆ្នាំ២០១១

**អភិបាលនៃគណៈអភិបាលខេត្ត**

**អ៊ុំ_សាមី**

**កន្លែងទទួលះ**

- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- អគ្គនាយកដ្ឋានពន្ធដារ
- ក្រុមប្រឹក្សាខេត្តព្រៃវែង "គោរពជូនជ្រាប"
- សាលាស្រុក-ក្រុង
- សាខាពន្ធដារខេត្ត
- និងស្ថាប័នពាក់ព័ន្ធ "ដើម្បីសហការអនុវត្ត"
- ឯកសារ-កាលប្បវត្តិ